# ដំណឹងផ្សេងៗ

# អំពីស្រុកចិន

ពិតមែនតែមានជាតិចិនច្រើននៅស្រុកខ្មែរយើង ប៉ុន្តែយើងស្គាល់ស្រុកនេះតិចណាស់ ។ ព្រះរាជបណ្ណាល័យទើបនឹងបានទទួលសៀវភៅភូមិសាស្ត្ររបៀបជំនួញនៅស្រុកចិន ដែលលោករើណោយុន បានរៀបរៀង ហើយបោះពុម្ពនៅក្រុងសៀងហៃ ។ យើងសូមអធិប្បាយអំពីអាណាខេត្តខ្លះដែលនៅក្នុងនគរធំនេះ ជូនលោកអ្នកដែលមើលសៀវភៅកម្ពុជសុរិយាទាំងអម្បាលម៉ាន សេចក្តីអធិប្បាយ គឺយើងដកស្រង់អំពីសៀវភៅភូមិសាស្ត្ររបស់លោករើណោយុននេះ ។

តាំងពី គ. ស. ១៩១២ ស្រុកចិននៅជាស្រុករេពុយព្លិក មានខេត្ត ២៨ មានស្រុកឯទៀតនៅក្រោមឱវាទ មានស្រុកមង្គលីនឹងស្រុកទីបេត៍ជាដើម នគរចិនបានជាឈ្មោះដូច្នេះ មកអំពីចង់ទុកកេរ្តិ៍ពួកដល់រាជ្យមហាក្សត្រមួយវង្សនៅស្រុកឱរ៉ុបគេហៅស្រុកចិនថា ស្រុកព្រៃឬអាណាចក្រកណ្តាល ។

ពីខាងត្បូងស្រុកចិននៅជាប់នឹងស្រុកដែលយើងបានស្គាល់ទាំងអស់គ្នា គឺស្រុកភូមាដែលជាស្រុកចំណុះអង់គ្លេស ហើយនឹងស្រុកតុងកឹងដែលនៅប្រទេសឥណ្ឌូស៊ីនខាងជើង ពីខាងលិចស្រុកចិនជាប់នឹងស្រុកឥណ្ឌៀរបស់អង់គ្លេស ពីខាងកើតជាប់នឹងមហាសមុទ្រមួយយ៉ាងធំ គឺសមុទ្រចិន ។

ភ្នំទាំងឡាយនៅស្រុកចិន ដែលមានបរិបូណ៌ដោយលោហជាតិដែលយើងបានឮគេនិយាយញយ ៗ នោះ គឺជងភ្នំហិមាល័យជាព្រំប្រទល់ស្រុកក្វិង្គនឹងស្រុកទីបេត៍ ហើយភ្នំដែលខ្ពស់ជាងគេនោះមានកំពស់ដល់ ៨.០០០ ម៉ែត្រ មានដីទួលខ្ពស់ ៗ នៅខេត្តយុនណាន់ ដែលជាប់មកស្រុកតុងកឹង ដីទួលនោះមានកំពស់ ២.៣០០ ម៉ែត្រពីសមុទ្រ ។

សត្វព្រៃ - នៅស្រុកចិនមានខ្លារខិន ខ្លាឃ្មុំ ខ្លាធំ ខ្ទីង សេះ លាព្រៃ ជ្រូកព្រៃ ។

សត្វស្រុក – សេះ លា ឱដ្ឋ ចៀម ពពែ សេះម្រេច ( អំពេស ) មានសត្វបក្សីចំនួន ១.០៣១ ពួក មានពស់នឹងមច្ឆាជាតិទាំងឡាយដ៏ច្រើន ។

រុក្ខជាតិ - នៅខាងជើងស្រុកចិនមានកប្បាស ស្រូវ ល្ង ស្រូវភោជសាលី ផ្ទៃ ថ្នាំ ស្រូវមិយ្យេត៍ ស្រូវអារសី ( millét , arge ) ឫស្សី ហើយនឹងរុក្ខផលាឯទៀតជាច្រើន ។ នៅខាងត្បូងស្រុកនេះមានដើមត្រាំ អំពៅ ក្រូច តែ ចេក ហើយនឹងឈើយ៉ាងល្អ ។ ។

នៅស្រុកចិនគេឃើញមានធ្យូង ដែក សំណប៉ាហាំងច្រើនមាននៅខាងត្បូងខេត្តយុន

ណាន់ មានមនុស្សធ្វើការលោហធាតុចំនួន ៣០.០០០ នាក់ មានស្ពាន់ សំណ អំបិល សំណមួយបែបទៀតដែលគេយកមកសិទ្ធធ្វើជាពុម្ពអក្សរ ឯទន្លេដែលនៅក្នុងស្រុកចិនខាងទិសនិរតី គឺទន្លេមេកុង ( ទន្លេធំ ) ហើយនឹងទន្លេសាលូអាន់ ដែលហូរធ្លាក់មកប្រទេសឥណ្ឌូស៊ីនយើងនេះ ខេត្រយុនណាន់ ដែលជាប់នឹងស្រុកតុងកឹង មានទីក្រុងឈ្មោះយុនណាន់ហ្វូ ៗ នេះតាំងនៅក្នុងទីវាលមួយដីមានជីជាតិល្អណាស់ ហើយអាកាសស្ងួតហែងផងនៅទីនោះ នៅខាងត្បូងខេត្រនេះមានសត្វដំរីខ្លះដែរ ។

កន្លែងដែលគេយកថ្មកែវនៅខេត្រគាលីហ្វូ ល្បីដោយសារថ្មកែវដែលគេយកមកនោះមានសរសៃសណ្ឋានដូចជាគំនូរល្អ ៗ ណាស់ ក្ងោសត្វជ្រូកនៅខេត្រយុនណាន់ ល្បីថាមានឱជារសឆ្ងាញ់ពីសាណាស់ ។

កំពង់ជំនួញសំខាន់ ៗ នៅស្រុកចិនរៀបរាប់តាមរបៀបធំតូចគឺសៀងហៃ ទៀនស៊ីន – ហាន់គីវ – ស៊ឹងតាវ – កង់តុង ។

*
* *

## អំពីកាសែតដែលមាននៅក្នុងផែនដីរបស់ជប៉ុន

តាមសៀវភៅកត់ហេតុរបស់ជប៉ុនដែលចេញផ្សាយក្នុង ព. ស. ២.៤៧៨ មានសេចក្ដីថាចំនួនកាសែតដែលបោះពុម្ពផ្សាយ ក្នុងឆ្នាំនេះមានចំនួន ៨.៣១០ ឈ្មោះ ញែកចេញជាកាសែតប្រភេទខែ - ត្រីមាស មានចំនួន ៦.៦៧៤ ឈ្មោះ ប្រភេទដែលចេញផ្សាយរាល់អាទិត្យ ៤៦១ ឈ្មោះ ប្រភេទដែលចេញផ្សាយរាល់ថ្ងៃ ១.១៧៥ ឈ្មោះ ។

ចំពោះកាសែតតូក្យូនិឈិឈិមប៊ូន នោះបោះពុម្ពផ្សាយរាល់ថ្ងៃប្រមាណ ១ ថ្ងៃ ១៥.០០០.០០០ ច្បាប់ ជាកាសែតមានដើមទុនច្រើនបំផុតក្នុងដែនជប៉ុន មានដើមទុន ១០ លានរៀលយេន មានយន្តហោះនាំដំណឹងយ៉ាងទាន់សម័យ មានអ្នកឲ្យដំណឹងទៅតោងប្រទេសក៏ច្រើន មានអ្នកដំណាងកាសែតក្នុងសមាគមសន្និបាតជាតិផង ។

តាមធម្មតាកាសែត បើមាននៅក្នុងប្រទេសណាច្រើន ប្រទេសនោះរមែងចំរើនដោយការសិក្សាពិតប្រាកដមែន ព្រោះកាសែតជាគ្រឿងវាស់សេចក្ដីចំរើនខាងការសិក្សាបានមួយផ្លូវដែរ។ ស្រង់អំពីកាសែតប្រមូលសារចុះថ្ងៃ ១២ ដេសមប្រ៍ ឆ្នាំ ១៩៣៩ ។

* *
*

## អំពីភូមា - អង់គ្លេស

*ដោយហេតុមានការផ្លាស់ប្តូរក្សត្រថ្មីនៃប្រទេសភូមា ស្រុកមណីបុរៈដែលជាស្រុកធ្លាប់ចំណុះភូមា ក៏ប្រែត្រឡប់រឹងទទឹងមិនព្រមចំណុះភូមាតទៅទៀត ទើបព្រះបាទចាក់កាយម៉ែងប្រទេសភូមាទ្រង់បង្គាប់ឲ្យចាត់បញ្ជូនកងទ័ពទៅប្រាបប្រាមស្រុកមណីបុរៈ លុះប្រាបប្រាមរាបទាបហើយក៏លើកកងទ័ពលូកចូលទៅក្នុងខេត្រដែនរបស់អង់គ្លេស គឺដែនអស្សាំ , ដែនចិត្តកង់, ដែនកៈសា ។ ចំណែកខាងរាជការអង់គ្លេសឃើញអាការភូមាកម្រើបអង់អាចលើករំលងចូលមកក្នុងខេត្រដែនដូច្នេះទើបកើតច្បាំងគ្នាឡើង ជាដំបូងក្នុងថ្ងៃទី ៥ ខែម៉ារ្ស ព. ស. ២៣៦៦ ក្នុងទីបំផុតភូមាដែលចេះប្រើវិធីចម្បាំងបែបបុរាណតែមួយយ៉ាង ក៏ចាញ់កងទ័ពអង់គ្លេសដែលមានយោធាទាហានស្ទាត់ជំនាញក្នុងវិធីចម្បាំងសម័យថ្មី ហើយភូមាសុំធ្វើសញ្ញាសន្តិភាពព្រមចុះចាញ់អង់គ្លេសក្នុងថ្ងៃ ២៤ ហ្វេវិយេ ព. ស. ២៣៦៨ ដោយភូមាព្រមប្រគល់ខេត្រម្រិត , ខេត្រថ្វាយ , ខេត្រតៈណាវសី នឹងខេត្រយៈខែឲ្យដល់អង់គ្លេស ហើយព្រមបង់ថ្លៃបង់ខាតឲ្យអង់គ្លេស ១០ លានរូប៉ីយ៍ ហើយរ៉ាប់រងថានឹងមិនចូលទៅបុករុកដល់ខេត្រមណីបុរៈ , ចិត្តកង់ , កៈសា តទៅទៀតឡើយ ។*